# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

## របាយការណ៍

## កិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីពាន់ប្រាំពីរ ខែកុម្ភៈ ថ្ងៃទី ដប់ពីរ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ A02 នៃទីស្តីការគណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពរបស់ឯកឧត្តម **សំ សុខផល** ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាលើកិច្ចការ របស់ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍មួយចំនួន និងមន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនោះ។ ជាបន្ទាប់ឯកឧត្តម **សំ សុខផល** បានបញ្ជាក់ជាថ្មីម្តងទៀត អំពីច្បាប់ប្រឆាំងអំពើពុករលួយថា ច្បាប់នេះកំពុងស្ថិតនៅក្រោមការ ទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ។ ឯកឧត្តមប្រធានបានជម្រាបអង្គប្រជុំផងដែរ អំពីការដកខ្លួនរបស់តំណាង UNDP ក្នុងឋានៈជាសហអ្នកសម្របសម្រួលក្នុងក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់នេះ និងតុលាការហើយ។

ឆ្លើយតបនឹងរឿងនេះលោក **កុយ នាម** តំណាង UNDP បានសុំអភ័យទោសចំពោះការខកខានមិនបានចូលរួម របស់លោកស្រី Anne-Isabelle Blateau និងលោកស្រី Sara នៅក្នុងកិច្ចប្រជុំនេះថា មិនមែនមកពីមូលហេតុនៃការដកខ្លួនចេញនោះទេ គឺដោយសារគាត់ជាប់រវល់ព្រោះមានកិច្ចការជាច្រើនជាមួយក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការទាក់ទងនឹង គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជាក្នុងឆ្នាំ ២០០៧។

លោក Pierre Espieu ទាក់ទងនឹងការធ្វើសេចក្តីព្រាងច្បាប់ ទីប្រឹក្សាក្រសួងយុត្តិធម៌ (ពីគម្រោង Appui à L' Etat de Droit របស់ប្រទេសបារាំង) បានមានប្រសាសន៍ថា ៖

- ច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រមបានពិនិត្យរួចហើយ

- សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវធ្វើឱ្យស្របទៅនឹងក្រមព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ
- ក្រមព្រហ្មទណ្ឌទើបតែសម្រេចបានត្រឹម ៧៥ ភាគរយតែប៉ុណ្ណោះ។

លោកជំទាវ **ចាន់ សុទ្ធាវី** អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ក៏បានធ្វើសេចក្តីរាយការណ៍ពីការងារដែលខាងក្រសួងយុត្តិធម៌បានធ្វើកន្លងមក និងកំពុងតែធ្វើក្នុងពេលបច្ចុប្បន្ននេះ ដូចជាច្បាប់ចាត់តាំងតុលាការគឺសព្វថ្ងៃកំពុងបិតនៅក្នុងក្រសួងយុត្តិធម៌ជាអ្នកធ្វើចំណែកច្បាប់លក្ខន្តិកៈ នៃអង្គចៅក្រមខាងក្រសួងយុត្តិធម៌បានពិនិត្យរួចហើយ និង បានបញ្ជូនទៅឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមជាមួយគ្នានោះដែរលោកជំទាវក៏បានសួរទៅខាងក្រុមប្រឹក្សាអ្នកច្បាប់ថា តើច្បាប់ទាំងនេះបានបញ្ជូនមកហើយឬនៅ ?

ឆ្លើយតបទៅនឹងសំណួរខាងលើ ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា ឯកឧត្តមមិនទាន់បានដឹង ឬក៏ទទួលនៅឡើយទេ ប៉ុន្តែឯកឧត្តមនឹងឱ្យខាងជំនួយការឆែកពិនិត្យ ពីបញ្ហានេះឡើងវិញ។

❖ **<u>ការរៀបចំចាត់ចែងបង្កើតកម្មវិធីសកម្មភាពប្រចាំឆ្នាំ ២០០៧ របស់ក្រុមការងារ បច្ចេកទេស-ចម្រុះ</u>**

ឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោងបានមានប្រសាសន៍សុំឱ្យ សមាជិកក្រុមការងារបច្ចេកទេសចម្រុះ ពិនិត្យទៅតាមអនុក្រុមនីមួយៗ ហើយឯកឧត្តមបាន លើកសំណើឱ្យ អនុក្រុមនីមួយៗ ធ្វើផែនការ សកម្មភាពរបស់ខ្លួន ។ មន្ត្រី PMU នៅក្នុងអនុក្រុមជាអ្នក សម្របសម្រួល ការងារនេះ។ ឯកឧត្តមបានលើក បង្ហាញគ្រួសៗពីតំណាងដៃគូអភិវឌ្ឍន៍ និងអនុក្រុមនីមួយៗ ដូចជាបារាំង តំណាងឱ្យក្រុមទីពីរ្ម UNDP តំណាងក្រុមទីមួយ រីឯ EWMI តំណាងក្រុមទីបួន ។ បន្ថែមពីលើនេះ ឯកឧត្តមបានសូមអញ្ជើញឱ្យតំណាងដឹកនាំក្រុមទីបួនមានជាមតិយោបល់ និងបង្ហាញខ្លួនផងដែរចំពោះ អង្គប្រជុំ ។

លោក Rajan ( EWMI) បានថ្លែងអំណរគុណចំពោះឯកឧត្តម ដែលបានជម្រាបឱ្យដឹងច្បាស់ អំពីរឿងតំណាង ក្រុមទីបួននេះ ដោយពីមុនមកលោកយល់ថា ប្រហែលជាមានដៃគូដឹកនាំការងារនេះរួចហើយ ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថា ខាងក្រសួងយុត្តិធម៌ត្រូវធ្វើការងារច្រើន គឺមិនមែនតែមួយ ក្រុមនោះទេ យ៉ាងតិចណាស់ក៏ពីរក្រុមដែរ។ ជាបន្ទាប់លោកស្រី Hotta Momoko តំណាងឱ្យអង្គការ Jica បានប្រកាស ថា Jica នឹងចូលរួមក្នុងក្រុមទីពីរ និងទីបួន។ ចំណែកខាងតំណាងក្រសួងអប់រំបានលើកឡើងថា ក្រសួងរបស់លោកមាន ឈ្មោះដល់ទៅបីក្រុម នោះឃើញថាមានការងារច្រើនជាងក្រសួងយុត្តិធម៌ទៅទៀត ដូច្នេះលោកបានសុំ បន្ថយមកត្រឹមពីរក្រុមវិញ គឺ ក្រុមពីរ និងក្រុមបីដែលមានការទាក់ទងនឹងកម្មវិធីសិក្សារបស់សិស្សនោះ។

ឯកឧត្តម **ប្រុក សារឿន** ក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា កន្លងមកក្រសួងមហាផ្ទៃតែងតែធ្វើការជាមួយក្រសួងយុត្តិធម៌ ហើយលោកនឹងស្នើសុំទៅថ្នាក់លើ ដើម្បីបញ្ជូនមនុស្សមកចូលរួមធ្វើការងារនេះដែរ។

❖ **ការពិភាក្សាអំពីថវិកាប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសចម្រុះ**

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថា គួរតែយកបញ្ហាថវិកាសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះមកពិចារណា។ ឯកឧត្តមបានជម្រាបថា បច្ចុប្បន្ននេះអង្គភាពគ្រប់គ្រងគម្រោង និងទីស្តីការគណៈរដ្ឋមន្ត្រីជាអ្នកទទួលបន្ទុកក្រុមការងារបច្ចេកទេសចម្រុះនេះ ដូច្នេះយើងចង់បានការ ឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ផងដែរ។ ទាក់ទងនឹងបញ្ហាថវិកា នេះតំណាង DANIDA ជម្រាបជូន អង្គប្រជុំឱ្យបានជ្រាបថាខាង DANIDA បានគ្រោងជួយថវិកាដល់ PMU & TWG ផងដែរ សូមមើល Website www.Phnom Penh.um.dk ស្តីពី ថវិកាប្រចាំឆ្នាំ២០០៧ របស់ DANIDA ។

ជាបន្ទាប់ខាង EWMI បានចោទជាសំណួរសួរថា ក្រមសីលធម៌ បានអនុមត័ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមរួចហើយ តើឯកសារនេះបានផ្សាយជា សាធារណៈដល់ចៅក្រម និងព្រះរាជអាជ្ញាដែលនៅតាមបណ្តាខេត្តក្រុងហើយ ឬនៅ?

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានឆ្លើយតបនឹងសំណួរនេះថា លោកនឹងធ្វើការទំនាក់ទំនងជាមួយនិងតុលាការកំពូល និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអំពីបញ្ហានេះរួច និងជម្រាបជូន EWMI។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានថ្លែងអំណរគុណដល់ខាងធនាគារពិភពលោក ដែលបានជួយធ្វើការងារបន្ថែម លើវិស័យកំណែទម្រង់ច្បាប់នេះ តាមរយៈគម្រោង Access to Justice For The Poor ។

លោក **លី តាយសេង** តំណាងគណៈមេធាវី បានថ្លែងអំណរគុណដល់ JICA ដែលមានគម្រោងថ្មីជួយដល់មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ហើយលោកបានជម្រាបជូនអង្គប្រជុំថា ខាងគណៈមេធាវីបានបញ្ជូនមេធាវីចំនួន ២៥នាក់ នៅគ្រប់ខេត្តក្រុង ដើម្បីការពារដល់កុមារ និងជនក្រីក្រ។

លោក **រស់ ឆាយ** មកពី AUSAID បានជម្រាបជូនដំណឹងដល់អង្គប្រជុំស្តីពីជំនួយ អូស្ត្រាលីជួយដល់ PMU និងខាងយុត្តិធម៌ព្រហ្មទណ្ឌ ដែលមានទឹកប្រាក់ចំនួន៣០លានដុល្លារអូស្ត្រាលីតាមរយៈគម្រោង CCJAP ជំហ៊ានទីបី (Phase III) មានរយៈពេលប្រាំឆ្នាំ ដែលនឹងចាប់ផ្តើមនៅខែមីនាខាងមុខនេះ។ ជាចុងក្រោយលោកបានថ្លែងអំណរគុណដល់DANIDA ដែលបានផ្តល់ជំនួយជាថវិកាក្នុងការទិញគ្រឿងសង្ហារឹមដល់តុលាការគំរូខេត្តកណ្តាលចេញពីទឹកប្រាក់ឧបត្ថម្ភចំនួនមួយលានដុល្លារអូស្ត្រាលី។

ជាចុងក្រោយឯកឧត្តម **ស៊ុយ ម៉ុងលាង** បានថ្លែងអំណរគុណចំពោះការប្រកាសដំណឹងទាំងឡាយ និងចំពោះ AUSAIDដែលបានជួយដល់តុលាការគំរូនៅខេត្តកណ្តាល ហើយឯកឧត្តមបានរំលឹកផងដែរស្តីអំពី

ការភ្ជាប់សកម្មភាពរបស់កំណែទម្រង់ច្បាប់ និងតុលាការទៅនឹងយុទ្ធសាស្ត្រជាតិ សម្រាប់កម្មវិធីអភិវឌ្ឍន៍ ២០០៦ ដល់២០១០។

❖ <u>សំណូមពរ</u> ៖

- តំណាងក្រសួងយុត្តិធម៌បានសុំឱ្យ JICA ជួយឧបត្ថម្ភថវិកាដល់វគ្គបណ្តុះបណ្តាលថៅក្រមផងដែរ មួយវិញទៀតខាងក្រសួងក៏ចង់ឱ្យខាង JICA ជួយធ្វើការបណ្តុះបណ្តាល ថៅក្រមដែលនៅឆ្ងាយ ឧទាហរណ៍ ដូចជានៅខេត្តសៀមរាប អំពីក្រមនីតិវិធីរដ្ឋប្បវេណី។
- ចំណែកខាងក្រសួងអប់រំក៏សុំឱ្យដៃគូអភិវឌ្ឍន៍ជួយធ្វើការបណ្តុះបណ្តាលដល់គ្រូបង្រៀន និងដល់ មន្ត្រីនាយកដ្ឋាននីតិកម្ម ចំនួន១០នាក់ នៅក្នុងក្រសួងអប់រំខាងផ្នែកច្បាប់ឱ្យបានប្រសើរជាងមុន ។
- គណៈមេធាវី សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ជួយខាងផ្នែកច្បាប់សម្រាប់កុមារ និងជនក្រីក្រ។
- ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានអំពាវនាវរកជំនួយសម្រាប់អនុវត្តសកម្មភាពរយៈពេលមធ្យម ដែលមានចែងក្នុងយុទ្ធសាស្ត្រជាតិ សម្រាប់កម្មវិធីអភិវឌ្ឍន៍ ២០០៦-២០១០ ។

ទីបញ្ចប់ ឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណចំពោះការចូលរួមពិគ្រោះយោបល់ក្នុងអង្គប្រជុំទាំងមូល និងសម្រេចថា កិច្ចប្រជុំនេះនឹងបន្តធ្វើនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខនេះ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងបួន និងសែសិបប្រាំនាទីល្ងាចនាថ្ងៃដដែល។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

**អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងលាង** **សេង រ៉ាន់ដា**

# បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
# នាថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧

១-ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ
២-ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
៣-លោក ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
៤-ឯកឧត្តម ផៃ សុខខេង ប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ
៥-លោក ឆុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
៦-លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
៧-លោក ជឹង ផេងស្រួយ ប្រធានក្រុមគម្រោងបណ្ណសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
៨-លោក ប៊ួន សុមុន្នី ប្រធានរដ្ឋបាលនិងហិរញ្ញវត្ថុ ក.ក.ច.ន.យ
៩-លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
១០- លោកស្រី ឈូក សារ៉ុម មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១១- លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១២- លោក ជ សៀកវែង CCJAPIII
១៣- លោកជំទាវ ចាន់ សុទ្ធាវី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
១៤- Kim Chhay Ly Project Managment Specialist USAID
១៥- Ben Schultz, CCJAPIII
១៦- Tan Michel, CCJAPIII
១៧- Yan Sokha, Project Assistant CCJAPIII
១៨- Prok Saroeun, Director Of Law Ministry Of Interrior
១៩- លោក ឡុង សុធា អនុប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងអប់រំយុវជន និងកីឡា
២០- Ly TaySeng, General Secretary of Bar Association
២១- Mr. Ros Chhay ( Senior Program Officer ) Australian Embassy
២២- Mr. Michael Engquist ( Consultant ) Danida
២៣- Mr. Phok Phira ( Staff )
២៤- Momoko Hotta ( Assistant Resident Representative, JICA )
២៥- Kumi Mochizuki ( Third Secretary ) Embassy of Japan in Phnom Penh
២៦- Mr. Pierre Espieu, Chef de project, Appui à L' Etat de Droit, France
២៧- Dominique Freslon , Conseiller de Coop'eration et d'Action Culturelle, Ambassade de France

២៨- Koy Neam, Program Manager ( UNDP )

២៩- Rajan Shah, Advisor EWMI

៣០- Alder Daniel, Legal Specialist WB